# កម្មវិធីរេដ+កម្ពុជា



ឧទ្យានជាតិកែប ខេត្តកែប
រូបភាព៖ ធី ហៀង

## ១. ទិដ្ឋភាពរួម

កម្ពុជា មានព្រៃឈើក្នុងវិសាលភាពធំទូលាយនៅឡើយ ដែលមានផ្ទៃដីសរុបច្រើនជាង ១០លានហិកតា ឬត្រូវជាជិត ៥៧%នៃផ្ទៃប្រទេសសរុប ( ទិន្នន័យគម្របព្រៃឈើឆ្នាំ ២០១០ )។ ប៉ុន្តែ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានបាត់បង់ព្រៃឈើប្រមាណ ២.៥៦លានហិកតា ( ១៩៦៥-២០១០ ) ពោល គឺអត្រាខ្ពស់នៃការបាត់បង់ព្រៃឈើធៀបនឹងប្រទេសដទៃទៀត។ មូលហេតុសំខាន់នៃការបាត់បង់ព្រៃឈើទាក់ទងជាសំខាន់ជាមួយបញ្ហាស្ថាប័ន និងអភិបាលកិច្ច និងអត្រាខ្ពស់នៃការអភិវឌ្ឍជាតិ។ ភស្តុតាងបង្ហាញថា សហគ្រាសកសិឧស្សាហកម្មខ្នាតធំបច្ចុប្បន្ន គឺជាកត្តាជម្រុញនៃការបាត់បង់ព្រៃឈើ។

តាមរយៈរេដ+ យើងអាចកាត់បន្ថយការបាត់បង់ព្រៃឈើ ពង្រឹងការអភិរក្ស និងលើកកម្ពស់ការគ្រប់គ្រង ព្រៃឈើឲ្យមាននិរន្តរភាព ដើម្បីជាប្រយោជន៍របស់ប្រជាជន ជាពិសេស ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទសត្វព្រៃ និងអាកាសធាតុ។ ដោយទទួលស្គាល់ពី សក្តានុពលនៃរេដ+



ទេសភាពព្រៃឈើពីកំពូលភ្នំបូគោ នៃខេត្តកំពត
រូបភាព៖ ធី ហៀង

កម្ពុជាស្ថិតក្នុងចំណោមប្រទេសដំបូង ក្នុងមហាតំបន់មេគង្គ ក្នុងការដោះស្រាយរេដ+ ដោយមានសកម្មភាពសាកល្បង ដែលចាប់ផ្តើមនៅឆ្នាំ២០០៨។ បន្ទាប់ពីកម្ពុជាបានចូលរួម ក្នុងកម្មវិធី UN-REDD នៅខែតុលា ឆ្នាំ២០០៩ អង្គការ UNDP និង FAO បានគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំផែនទីបង្ហាញផ្លូវអំពី ការត្រៀមខ្លួនរួចជាស្រេចសម្រាប់ការអនុវត្តកម្មវិធីរេដ+កម្ពុជា។



តំណាងក្រុមជនជាតិដើមភាគតិចនៅតាមបណ្តាខេត្តទាំង១៥ ចូលរួមក្នុងសិក្ខាសាលាជ្រើសរើសក្រុមប្រឹក្សាយោបល់នៅថ្នាក់ជាតិ
រូបភាព៖ NTFP-EP

## ២. ការត្រៀមលក្ខណៈនៅកម្ពុជា

ដើម្បីគាំទ្រដល់ការអនុវត្តផែនទីបង្ហាញផ្លូវនេះ កម្មវិធីរេដ+នៅកម្ពុជា ត្រូវបានបង្កើតឡើងនូវលទ្ធផលអនុវត្តន៍ចំបងៗ ចំនួនបួន៖

**លទ្ធផលទី១៖ ការគ្រប់គ្រងដំណើរការរបស់ជាតិឲ្យមានប្រសិទ្ធភាព ដើម្បីត្រៀមលក្ខណៈសម្រាប់រេដ+ និងធ្វើឲ្យអ្នកពាក់ព័ន្ធបានចូលរួមស្របតាមគោលការណ៍នានា**

សមាភាគនេះ នឹងត្រូវបានបង្កើតឡើង គាំទ្រឲ្យមានការចាត់ចែងគ្រប់គ្រង និងការចូលរួមឲ្យបានសមស្របពីភាគីពាក់ព័ន្ធសម្រាប់ការត្រៀមលក្ខណៈជាស្រេចដើម្បីអនុវត្តរេដ+។

### លទ្ធផលទី២៖ ការកសាងយុទ្ធសាស្ត្ររេដ+ និងក្របខ័ណ្ឌអនុវត្តន៍

សមាសភាពនេះ នឹងគាំទ្រក្រុមការងាររេដ+កម្ពុជា និងស្ថាប័នពាក់ព័ន្ធដើម្បីវាយតម្លៃយុទ្ធសាស្ត្រដែលសមស្រប សម្រាប់រេដ+ដែលបានស្នើឡើងនៅក្នុងដំណាក់កាលកសាងផែនទីបង្ហាញផ្លូវ។ សមាសភាគនេះ ក៏នឹងវិភាគយុទ្ធសាស្ត្រនានាបន្ថែមទៀត ដើម្បីបង្កើតធាតុផ្សំសំខាន់ៗ នៃក្របខ័ណ្ឌអនុវត្តរេដ+ផងដែរ ដែលរួមទាំងបង្កើតយន្តការមូលនិធិ ការបែងចែកផលប្រយោជន៍ និងកសាងផែនការនានាសម្រាប់គោលនយោបាយចាំបាច់ និងកំណែទម្រង់ច្បាប់សម្រាប់អនុវត្តន៍រេដ+ផងដែរ។

REDD+ CAMBODIA


**ព័ត៌មានទំនាក់ទំនងលេខាធិការដ្ឋាន**

**លោក យុន វឌ្ឍនា**
ប្រធានលេខាធិការដ្ឋានក្រុមការងាររេដ+កម្ពុជា

#៤០ មហាវិថីនរោត្តម ភ្នំពេញ កម្ពុជា
លេខទូរស័ព្ទ៖ (+៨៥៥) ២៣ ២២៤ ២៥១
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org


### លទ្ធផលទី៣៖ កែលម្អសមត្ថភាពដើម្បីគ្រប់គ្រងរេដ+នៅថ្នាក់ក្រោមជាតិ

សមាសភាពនេះនឹងគាំទ្រដល់ការរៀបចំបង្កើតគម្រោងសាកល្បងរេដ+ ដែលភាពជោគជ័យនៃការអនុវត្តគម្រោងទាំងនេះ នឹងបង្ហាញពីសារៈសំខាន់នៃការបង្កើតប្រព័ន្ធរេដ+នៅថ្នាក់ជាតិ។ ការកសាងសមត្ថភាពថ្នាក់ខេត្តក្នុង ខេត្តមណ្ឌលគីរី ក៏នឹងបានទទួលការគាំទ្រផងដែរ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តរេដ+ នៅថ្នាក់ក្រោមជាតិ ដែលនេះជាផ្នែកមួយនៃដំណើរការពង្រីកការអនុវត្តរេដ+ ទៅថ្នាក់ជាតិ។


*ការពិភាក្សារបស់ក្រុមជនជាតិដើមភាគតិចក្នុងដំណើរការនៃការជ្រើសរើសក្រុមប្រឹក្សាយោបល់*
*រូបភាព៖ NTFP-EP*

### លទ្ធផលទី៤៖ បង្កើតប្រព័ន្ធពិនិត្យតាមដាន និងសមត្ថភាពក្នុងការការអនុវត្ត

សមាសភាគនេះ នឹងបង្កើតប្រព័ន្ធថ្នាក់ជាតិដើម្បីពិនិត្យតាមដានព្រៃឈើ និងផ្តល់ការគាំទ្រដល់ស្ថាប័ននានានៃរដ្ឋាភិបាល ដើម្បីប្រមូល និងចងក្រងទិន្នន័យគោល ដែលចាំបាច់ ក្នុងការតាមដានគម្របព្រៃឈើ និងមេគុណនៃការបំភាយសម្រាប់សេណារីយ៉ូយោង។ការគាំទ្រពីរដ្ឋាភិបាលជប៉ុនក៏រួមចំណែកក្នុងការបង្កើតប្រព័ន្ធពិនិត្យតាមដាននេះផងដែរ។

## ៣. ការត្រៀមលក្ខណៈ៖ ដៃគូសំខាន់ៗ

ការត្រៀមលក្ខណៈដើម្បីរេដ+ គឺជាការប្រឈមមួយដែលមិនអាចសម្រេចបាន តាមរយៈស្ថាប័នណាតែមួយនៃរដ្ឋាភិបាលនោះឡើយ ប៉ុន្តែទាមទារឲ្យមានភាពជាដៃគូយ៉ាងសកម្មជាមួយដៃគូជាច្រើន។ ដៃគូទាំងនោះ រួមមាន សង្គម-ស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេស និងដៃគូអភិវឌ្ឍន៍ទ្វេភាគីនិងពហុភាគីផងដែរ។ កម្ពុជាមានសំណាង ដោយសារមានដៃគូអភិវឌ្ឍន៍ជាច្រើន ជួយក្នុងដំណើរការត្រៀមលក្ខណៈដើម្បីរេដ+។


*ទេសភាពព្រៃឈើលើកំពូលភ្នំបូគោ នៃខេត្តកំពត*
*រូបភាព៖ ធី ហៀង*

ដៃគូអភិវឌ្ឍន៍ទាំងនោះមានជាអាទិ៍ កម្មវិធីUN-REDD (ដែលអនុវត្តតាមរយៈ FAO, UNDP និង UNEP) កម្មវិធី CAM-REDD ដែលគាំទ្រដោយប្រទេសជប៉ុន និងមូលនិធិដៃគូកាបូនព្រៃឈើនៃធនាគារពិភពលោក និងការផ្តល់មូលនិធិពីUSAID តាមរយៈកម្មវិធីកាត់បន្ថយការបំភាយកាបូនព្រៃឈើនៅអាស៊ី(LEAF)។អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា ក៏កំពុងអនុវត្តគម្រោងនេះ ដើម្បីកសាងសមត្ថភាព សម្រាប់រេដ+នៅថ្នាក់មូលដ្ឋានផងដែរ។